ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងរវាងនាយិកាក្រុមហ៊ុនសុខៈប៊ូទិកនិងតំណាងកម្មករនិយោជិក ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ ២០២១វេលាម៉ោង ៩ និង ៣០នាទី នៅក្នុងក្រុមហ៊ុនសណ្ឋាគារសុខៈប៊ូទិកមានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិក។

នៅក្នុងអង្គប្រជុំនេះនាយិកាក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិកទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរបស់ក្រុមហ៊ុនថា ដោយសារការរីករាលដាលនិងចម្លងនៃជំងឺរលាកសួតប្រភេទថ្មីCovid-19ដែលជាហេតុបណ្តាលអោយមានផលប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោកហើយក៏ជាហេតុដែលធ្វើអោយក្រុមហ៊ុនទទួលរងការខាតបង់ មិនមានប្រាក់ចំណូលសំរាប់ទ្រទ្រង់ប្រតិបត្តិការណ៍បន្តទៀតបាន។

ហេតុដូចនេះក្រុមហ៊ុនបានសំរេចចិត្តធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិកទាំងអស់ ចំនួន១១នាក់ (ស្រី០១នាក់)រយៈពេល៦០ថ្ងៃដោយគិតចាប់ពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២១ រហូតដល់ទី០៦ ខែតុលា ឆ្នាំ២០២១ នៅក្នុងកំឡុងពេលនៃការព្យួរនេះកម្មករនិយោជិកនឹងមិនទទួលបានអត្ថប្រយោជន៍អ្វីពីក្រុមហ៊ុនឡើយ។ អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១០និង៣០នាទីនាថ្ងៃខែឆ្នាំដដែល ដោយសារភាគីទាំងសងខាងមានការស្និទ្ធស្នាលនិងយោគយល់គ្នាក្រោមស្មារតីទទួលនិងសហការគ្នាយ៉ាងរលូន។

ថ្ងៃពុធ៥រោចខែទុតិយាសាឍឆ្នាំឆ្លូវត្រីស័ក ព.ស២៥៦៥
សៀមរាប ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០២១

ហត្ថលេខា និងត្រា នាយិកា

ជុនតាប់

តំណាងកម្មករនិយោជិក

Pok Ser ; Sum Seam